ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៧....សហវ.ខ្មា

# សារាចរណែនាំ
## ស្តីពី
## ការតម្កល់ប្រាក់កក់ស្នើសុំអាជ្ញាប័ណ្ណសាងសង់កាស៊ីណូ

យោងសេចក្តីជូនដំណឹងលេខ ១០៨ សជណ.សរ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុនដែលមានបំណងស្នើសុំអាជ្ញាប័ណ្ណសាងសង់កាស៊ីណូ (សជណ) នៅតាមព្រំដែនប្រទេសកម្ពុជាជាមួយប្រទេសជិតខាង ត្រូវអនុវត្តទៅតាមប្រការដូចខាងក្រោម ៖

**ប្រការ១**: ចំពោះក្រុមហ៊ុនដែលមានបំណងសុំអាជ្ញាប័ណ្ណសាងសង់កាស៊ីណូ នៅតាមព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង គឺតម្រូវឲ្យបង់ប្រាក់កក់ចំនួន ១,០០០,០០០ (មួយលាន) ដុល្លារអាមេរិក ហើយមានសុពលភាពត្រឹមរយៈពេលមួយ (០១) ឆ្នាំ ។ ក្នុងករណីក្រុមហ៊ុនមិនបានដំណើរការសាងសង់ក្នុងរយៈពេលដែលបានកំណត់ខាងលើ អាជ្ញាប័ណ្ណនោះត្រូវទុកជាមោឃៈ ហើយប្រាក់កក់មិនត្រូវបានប្រគល់ជូនក្រុមហ៊ុនវិញឡើយ ។

**ប្រការ២**: ប្រាក់កក់ត្រូវតម្កល់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅក្នុងគណនីថវិការដ្ឋលេខ 000000001333 នៅធនាគារជាតិ នៃកម្ពុជា ។

**ប្រការ៣**: ក្រុមហ៊ុនអាចដកប្រាក់កក់វិញបានជាពីរ (០២) ដំណាក់កាល ៖

-ដំណាក់កាលទី១: ៥០% (ហាសិបភាគរយ) នៅពេលការសាងសង់សម្រេចបាន ៥០% នៃគម្រោងទាំងមូល។

-ដំណាក់កាលទី២: ៥០% (ហាសិបភាគរយ)ទៀត នៅពេលការសាងសង់ចប់ជាស្ថាពរ ។

**ប្រការ៤:** ទទួលបានសារាចរណែនាំនេះ នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និង ក្រុមហ៊ុនដែលមានបំណងស្នើសុំអាជ្ញាប័ណ្ណសាងសង់កាស៊ីណូ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

សារាចរណែនាំនេះ មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១២

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- គ្រប់សាលារាជធានី-ខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ